# ការប្រកាសប្រាប់ពីការផ្លាស់ប្តូរដែលមកពីព្រះជាម្ចាស់

ព្រះយេស៊ូវត្រូវបានគេ
**ផ្តន្ទាទោស.....**

ដើម្បីឲ្យខ្ញុំត្រូវបាន
**អភ័យទោសឲ្យ (១)**

ព្រះយេស៊ូវត្រូវ
**រងរបួស.....**

ដើម្បីឲ្យខ្ញុំអាចត្រូវបានប្រោសឲ្យ
**ជាសះស្បើយ (២)**

ព្រះយេស៊ូវត្រូវបាន **ត្រូវរាប់**
**ជាមានអំពើបាប ដោយសារ**
**តែអំពើបាបរបស់យើង ......**

ដើម្បីឲ្យខ្ញុំអាចត្រូវរាប់
**ជាសុចរិត ដោយសារសេចក្តី**
**សុចរិតរបស់ទ្រង់ (៣)**

ព្រះយេស៊ូវត្រូវបានសុគត
នៅក្នុង **សេចក្តីស្លាប់របស់**
**យើងរាល់គ្នា.....**

ដើម្បីឲ្យខ្ញុំអាច
**ទទួលបាននូវជីវិតរបស់ទ្រង់ (៤)**

ព្រះយេស៊ូវបានស៊ូទ្រាំនឹង
**ភាពក្រីក្រ** របស់យើង .....

ដើម្បីឲ្យខ្ញុំអាចចែករំលែក
**ទ្រព្យសម្បត្តិដ៏ច្រើនក្រៃលែង**
របស់ទ្រង់ (៥)

ព្រះយេស៊ូវបានទទួល
**សេចក្តីអាម៉ាស់**
របស់យើង.....

ដើម្បីឲ្យខ្ញុំអាចចែករំលែក
**នូវសិរីល្អរបស់ទ្រង់ (៦)**

ព្រះយេស៊ូវបានស៊ូទ្រាំការ
**បដិសេធ** របស់យើង ....

ដើម្បីឲ្យខ្ញុំបាន**ទទួលយក**
ការទទួលស្គាល់ពីព្រះវរបិតា (៧)

ព្រះយេស៊ូវបាន
**ទទួលរងបណ្តាសា.....**

ដើម្បីឲ្យខ្ញុំអាចចូលទៅក្នុង
**ព្រះពរនៃព្រះជាម្ចាស់ (៨)**

(១&២) អេសាយ ៥៣ : ៤-៥
(៣) ២កូរិនថូស ៥ : ២១
(៤) ហេព្រើរ ២ : ៩
(៥) ២កូរិនថូស ៨ : ៩
(៦) ហេព្រើរ ១២ : ២
(៧) អេភេសូរ ១ : ៥-៦
(៨) កាឡាទី ៣ : ១៣

**អេសាយ ៥៣: ៤-៥** ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា ៥ តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់។

**២កូរិនថូស ៥: ២១** ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង។

**ហេព្រើរ ២: ៩** តែយើងឃើញព្រះយេស៊ូវវិញ ដែលព្រះបានធ្វើឲ្យទាបជាងពួកទេវតាបន្តិច ទ្រង់ពាក់សិរីល្អ និងល្បីព្រះនាម ទុកជាមកុដ ដោយព្រោះទ្រង់បានរងទុក្ខសុគត ដើម្បីនឹងភ្លក់សេចក្ដីស្លាប់ជំនួសមនុស្សទាំងអស់ ដោយនូវព្រះគុណនៃព្រះ។

**២កូរិនថូស ៨: ៩** ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ថាទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្ដីកម្ររបស់ទ្រង់។

**ហេព្រើរ ១២: ២** ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្ដើម ហើយជាមេសំរេចសេចក្ដីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅឈើឆ្កាង ទាំងមើលងាយចំពោះសេចក្ដីអាម៉ាស់ខ្មាសនោះ ឲ្យតែបានសេចក្ដីអំណរដែលនៅចំពោះទ្រង់ រួចទ្រង់ក៏គង់ខាងស្តាំបល្ល័ង្កនៃព្រះ។

**អេភេសូរ ១: ៥-៦** ពីព្រោះទ្រង់បានតម្រូវយើងរាល់គ្នាទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់ ៦ ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្តមរបស់ទ្រង់ ដែលបានផ្តល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ ។

**កាឡាទី ៣: ១៣** ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីសេចក្ដីបណ្ដាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រូវបណ្ដាសាជំនួសយើងរាល់គ្នា (ដ្បិតមានសេចក្ដីចែងទុកមកថា «ត្រូវបណ្ដាសាហើយ អ្នកណាដែលត្រូវព្យួរនៅលើឈើ»)។

**បកប្រែដោយ: ONE -2- ONE CAMBODIA**
**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC02